

# គោលការណ៍រួមសម្រាប់ការបន្សាំ
## ( ជេ.ភី.អេ-JPA )

### គំនិតផ្តួចផ្តើមរបស់សង្គមស៊ីវិលដើម្បីលើកកម្ពស់ប្រសិទ្ធភាព និងសមភាពនៃការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ




[1] រូបថត៖ ក្នុងសិក្ខាសាលា នៅទីក្រុងណៃរ៉ូប៊ី ដេភីអេ ត្រូវបានធ្វើបច្ចុប្បន្នភាពតាមរយៈការពិភាក្សាក្នុងចំណោមអ្នកចូលរួម ពីបណ្តាញនានាជាដៃគូក្នុងប្រទេសចំនួន១២ ©ឃៃរ ដាណឺម៉ាក

## អំពីគោលការណ៍រួមសម្រាប់ការបន្សាំ (ជេ.ភី.អេ)

គោលការណ៍រួមសម្រាប់ការបន្សាំ គឺជាសេចក្តីថ្លែងការមួយរបស់អង្គការសង្គមស៊ីវិលមកពីជុំវិញពិភពលោកស្តីពីអ្វីដែលពួកគេពិចារណាចាត់ទុកថាជាគន្លឹះសម្រាប់រៀបចំផែនការបន្សាំ និងការអនុវត្តការបន្សាំដ៏ល្អមួយ។ គោលការណ៍ទាំងនោះគឺជាឧបករណ៍មួយដើម្បីធានាថាគោលនយោបាយ និងផែនការជាតិបានឆ្លើយតបនឹងសេចក្តីត្រូវការនានា និងបានបំពេញនូវសិទ្ធិរបស់ក្រុមមនុស្សដែលងាយរងគ្រោះបំផុត ដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។

ជេ.ភី.អេ ត្រូវបានរៀបចំឡើងក្នុងកំឡុងឆ្នាំ២០១៤ និង២០១៥ ដោយបណ្តាញអង្គការសង្គមស៊ីវិល ដែលធ្វើការលើការប្រែប្រួលអាកាសធាតុពីប្រទេសនៅក្នុងទ្វីបអាហ្វ្រិក អាស៊ី និងអាមេរិកឡាទីន នៅក្រោមគម្រោងមួយដែលគេស្គាល់ថាជា **សម្លេងភាគខាងត្បូងស្តីពីការបន្សាំ** (អេស.វី.អេ-SVA)។ ជេ.ភី.អេ បានរៀបចំឡើង និងវិវត្តន៍ដោយចំណាយពេលយ៉ាងយូរ ហើយក៏បានកែសម្រួលជាច្រើនដង បន្ទាប់ពីធ្វើការសាកល្បងនៅក្នុងប្រទេសចំនួន ១២ និងទទួលបានមតិកែលម្អពីអ្នកពាក់ព័ន្ធផ្សេងៗគ្នាផងដែរ។ ឯកសារកែសម្រួលលើកទី៣ នេះ ត្រូវបានបញ្ចប់នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៥។

## តើ ជេ.ភី.អេ ត្រូវបានរៀបចំឡើងយ៉ាងដូចម្តេច?




## ការប្រើប្រាស់គោលការណ៍ ជេ.ភី.អេ

បទពិសោធន៍របស់ដៃគូរបស់ អេស.វី (Southern Voice on Adaptation ) កន្លងមកមិនត្រឹមតែបានកែសម្រួលមាតិកានៃ **ជេ.ភី.អេ** ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងស្វែងយល់អំពីថាតើ **ជេ.ភី.អេ** អាចដាក់ជាការប្រើប្រាស់ដ៏ល្អមួយក្នុងបរិបទផ្សេងៗគ្នាយ៉ាងដូចម្តេច។

**គោលការណ៍រួមបានប្រើប្រាស់ក្នុងរបៀបបីយ៉ាងទូលំទូលាយ:**

- **ដើម្បីធ្វើឱ្យមានឥទ្ធិពលដល់ដំណើការរៀបចំគោលនយោបាយ** តាមរយៈការស្រាវជ្រាវព័ត៌មាន និងយុទ្ធសាស្រ្តតស៊ូមតិ។
- **ដើម្បីពង្រឹងសមត្ថភាព** តាមរយៈការកំណត់បញ្ហាសម្រាប់ការសិក្សាដោយសង្គមស៊ីវិល និងអ្នកអនុវត្តផ្សេងៗទៀត និង
- **ដើម្បីលើកកម្ពស់កិច្ចពិភាក្សា** តាមរយៈការផ្តល់នូវរបៀបវារៈសម្រាប់ការពិភាក្សាជាមួយរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធផ្សេងៗទៀត។

គោលការណ៍រួមនេះ ត្រូវបានកំណត់ជាមធ្យោបាយមួយ ដែលជាទូទៅអាចអនុវត្តបាននៅក្នុងបរិបទនៃគ្រប់ប្រទេស។ ស្របពេលដែលគោលការណ៍អាចប្រើប្រាស់ក្នុងទម្រង់បែបនេះ និងក្នុងករណីភាគច្រើន គោលការណ៍នេះចាំបាច់ត្រូវការកែតម្រូវឱ្យស្របតាមបរិបទជាក់លាក់។ ជំហានដំបូងក្នុងការប្រើប្រាស់គោលការណ៍រួមនេះ គឺដើម្បីធានាថាពួកគេបានបង្ហាញនូវវិធីមួយដែលសមស្របដល់ក្រុមគោលដៅ។ ជំហានបន្តរួមមួយគឺប្រើប្រាស់ **ជេ.ភី.អេ** ដើម្បីវិភាគគោលនយោបាយនានាដែលមានស្រាប់ ក្នុងការកំណត់ចំណុចខ្វះខាត និងវិស័យដែលការងារតស៊ូមតិអាចនឹងផ្តោតទៅលើនោះ។ ដូច្នេះ ជាការគាំទ្រដល់ការរៀបចំ **ជេ.ភី.អេ** កម្មវិធី Southern Voice បានផលិតឧបករណ៍វាយតម្លៃមួយជាស្តាពរស្តីពីគោលការណ៍ និងលក្ខណៈវិនិច្ឆ័យ។ ឯកសារនេះអាចរកបាននៅលើគេហទំព័ររបស់យើង www.southernvoices.net

## គោលការណ៍រួមសម្រាប់ការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ កែសម្រួលលើកទី៣ នៅខែវិច្ឆិកា ឆ្នាំ២០១៥

*ក្របខ័ណ្ឌជាតិសម្រាប់ការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ គឺកាន់តែមានសមភាព និងប្រសិទ្ធភាពប្រសើរឡើងនៅពេលដែល៖*

| គោលការណ៍ | លក្ខណៈវិនិច្ឆ័យ |
|---|---|
| ក. ការបង្កើត ការអនុវត្ត និងការត្រួតពិនិត្យគោលនយោបាយ និងផែនការបន្សុំា ដោយមានការចូលរួម និងការរួមបញ្ចូល។ | ១. ពហុភាគីពាក់ព័ន្ធ (រួមទាំងសង្គមស៊ីវិល រដ្ឋបាលថ្នាក់ក្រោមជាតិ ស្ថាប័នសិក្សាស្រាវជ្រាវ វិស័យសិក្សាធិការ វិស័យឯកជន និងជនជាតិដើមភាគតិច...) បានចូលរួមនៅក្នុងការកំណត់ ជ្រើសរើស និងចាត់អាទិភាព និង នៅក្នុងដំណាក់កាលអនុវត្ត និងការត្រួតពិនិត្យតាមដាន។<br>២. ចំណេះដឹង សំណូមពរ និងបទពិសោធន៍របស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ត្រូវបានដាក់បញ្ចូល។<br>៣. ផែនការ និងគោលនយោបាយត្រូវបានផ្សព្វផ្សាយជាសាធារណៈ តាមមធ្យោបាយដែលប្រជាពលរដ្ឋមូលដ្ឋានអាចងាយយល់ ចូលរួម និងទទួលយកបាន។ |
| ខ.មូលនិធិសម្រាប់ការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ ត្រូវបានប្រើប្រាស់យ៉ាងមានប្រសិទ្ធភាព និងគ្រប់គ្រងប្រកបដោយតម្លាភាព និងសុច្ចរិតភាព។ | ១. ការអនុវត្ត និង ហិរញ្ញប្បទាន នៃផែនការបន្សុំាត្រូវបានត្រួតពិនិត្យនៅពេលណាមួយ ដោយតំណាងស្ថាប័ននៃអង្គការសង្គមស៊ីវិល។<br>២. មូលនិធិបន្សុំាដែលអាចរកបាន ត្រូវបែងចែកតាមរយៈដំណើរការវិភាជន៍ប្រកបដោយតម្លាភាព។<br>៣. ដៃគូពាក់ព័ន្ធមានសិទ្ធិចូលរួមពេញលេញ និងដោយសេរី ក្នុងការត្រួតពិនិត្យ មូលនិធិបន្សុំា ដែលបាននិងកំពុងត្រូវបានចំណាយ |

| គោលការណ៍ | លក្ខណៈវិនិច្ឆ័យ |
| --- | --- |
| | (ហិរញ្ញវត្ថុ និង ដំណើរការ)។<br>៤. មានយន្តការមួយត្រូវបានបង្កើតឡើងដើម្បីធានាពីការការពារ ប្រឆាំងទៅនឹងការផ្តួចផ្តើមណាមួយដែលនាំឲ្យមាន ឬ ធ្វើឲ្យមានផលប៉ះពាល់អវិជ្ជមាន។<br>៥. មានយន្តការសុវត្ថិភាពមួយសម្រាប់ការសម្តែងការកង្វល់ និងស្វែងរកសំណង។ |
| គ. រដ្ឋបាលគ្រប់ជាន់ថ្នាក់ ស្ថាប័នរាជរដ្ឋាភិបាល ត្រូវមានទំនួលខុសត្រូវច្បាស់លាស់ និងធានាថា មានធនធានសមស្របដើម្បីបំពេញការងារ។ | ១. ផែនការការបន្សុាំថ្នាក់ជាតិផ្តល់សិទ្ធិអំណាចដើម្បីជួយឱ្យវិស័យផ្សេងៗរបស់រាជរដ្ឋាភិបាលអាចធ្វើការរួមគ្នាបានប្រកបដោយភាពស្រុះស្រួលល្អ ក្នុងមធ្យោបាយរួមគ្នា។<br>២. ការផ្តួចផ្តើម និងគម្រោងតាមវិស័យដែលមានស្រាប់ ត្រូវបានជម្រុញ និងធ្វើឱ្យប្រសើរឡើងដោយមានការយកចិត្តទុកដាក់ចំពោះការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយ។<br>៣. មូលនិធិសម្រាប់ការបន្សុាំត្រូវបានបែងចែក និងផ្តល់ឱ្យបានច្បាស់ និងសមស្របនៅក្នុងថវិកាជាតិ និងគោរពទៅតាមការបែងចែកតាមវិស័យដោយសមស្រប។<br>៤. ផែនការបន្សុាំនៅថ្នាក់មូលដ្ឋាន ត្រូវបានសម្របសម្រួលតាមរយៈយន្តការនានា ដើម្បីធានាឱ្យមានទំនាក់ទំនង និងភាពស៊ីសង្វាក់គ្នាទៅនឹងគោលនយោបាយ និងយុទ្ធសាស្ត្រជាតិបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ។ |
| ឃ. ផែនការការបន្សុាំមូលដ្ឋានត្រូវបានបង្កើត តាមរយៈវិធីសាស្ត្រដែលបានធ្វើឱ្យប្រសើរឡើងនូវភាពធន់របស់សហគមន៍ និងប្រព័ន្ធអេកូឡូស៊ី។ | ១. សហគមន៍ដែលរងផលប៉ះពាល់ដោយការប្រែប្រួលអាកាសធាតុបានចូលរួមនៅក្នុងការកំណត់ជម្រើសការបន្សុាំ និងការចាត់អាទិភាព។<br>២. ផែនការការបន្សុាំរបស់សហគមន៍ ត្រូវបានរៀបចំ និងដាក់បញ្ចូលជាអាទិភាពនៅក្នុងផែនការអភិវឌ្ឍរបស់រដ្ឋបាលមូលដ្ឋាន ឃុំ សង្កាត់។<br>៣. ប្រភពធនធានសំខាន់ៗ ត្រូវបានត្រៀមបម្រុង ដើម្បីធានា និងគាំទ្រការអនុវត្តផែនការបន្សុាំមូលដ្ឋាន។<br>៤. ការវិភាជន៍ហិរញ្ញវត្ថុត្រូវផ្តល់ឱ្យដោយមានការប្តេជ្ញាចិត្ត ចំពោះកម្មវិធីរយៈពេលយូរ ដើម្បីគាំទ្រសហគមន៍ងាយរងគ្រោះ។ |

| គោលការណ៍ | លក្ខណៈវិនិច្ឆ័យ |
|---|---|
| ង. កសាងភាពធន់នៃក្រុមងាយរងគ្រោះបំផុតទៅនឹងការប្រែប្រួលអាកាសធាតុ ត្រូវបានលើកកម្ពស់។ | ១. ផែនការ និងគោលនយោបាយ ចូលរួមដោះស្រាយបញ្ហាដែលបង្កផលប៉ះពាល់ដល់ក្រុមស្ត្រី បុរស ក្មេងប្រុស និងក្មេងស្រី។<br>២. ក្រុមមនុស្សដែលងាយរងគ្រោះបំផុតទៅនឹងលក្ខខណ្ឌសង្គម វប្បធម៌ សេដ្ឋកិច្ច និងបរិស្ថាន ត្រូវបានកំណត់ច្បាស់លាស់ និងជាក្រុមគោលដៅ។<br>៣. គំនិតផ្តួចផ្តើមត្រូវយកមកពិចារណានូវតម្រូវការ និងសមត្ថភាពផ្សេងៗ របស់ស្ត្រី និងបុរស ទៅតាមអាយុ និងភេទ។<br>៤. គំនិតផ្តួចផ្តើមក្នុងការលើកកម្ពស់សមភាពសង្គម ការផ្សារភ្ជាប់ និងការការពារជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ |
| ច.មានការវិនិយោគសមស្របមួយរវាងការពង្រឹងជំនាញ និងសមត្ថភាពសម្រាប់ការបន្សាំ និងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត។ | ១. ធនធានដ៏សមស្របមួយ ត្រូវបានបង្កើតឡើងដែលអាចប្រើបាន ដើម្បីបង្កើនប្រសិទ្ធភាពនៃស្ថាប័នដែលទទួលខុសត្រូវ សម្រាប់អនុវត្ត និងគ្រប់គ្រង ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។<br>២. មានធនធានដ៏សមស្របមួយ ដែលអាចរកបានសម្រាប់ការបង្កើន ការយល់ដឹងជាសាធារណៈ និងការអប់រំអំពីការប្រែប្រួលអាកាសធាតុ។<br>៣. ផែនការវិនិយោគមានការដាក់បញ្ចូលជាគោលដៅសម្រាប់ការអភិវឌ្ឍសមត្ថភាពរបស់សហគមន៍ ធនធានធម្មជាតិ និងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត។<br>៤. សមត្ថភាពរបស់មនុស្សក្នុងមូលដ្ឋាន និងរចនាសម្ព័ន្ធ របស់ពួកគេត្រូវបានបង្កើតឡើង នៅក្នុងរបៀបដែលរួមចំណែកដល់ក្នុងការផ្តល់សិទ្ធិអំណាចដល់បុគ្គល និងសហគមន៍។ |
| ឆ. ការរៀបចំផែនការ និងគោលនយោបាយ ត្រូវឆ្លើយតបទៅនឹងភស្តុតាងវិទ្យាសាស្ត្រថ្មីៗអំពីឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ និងដំណោះស្រាយទាំងពេលបច្ចុប្បន្ន និងអនាគត | ១. ផែនការបន្សាំ ត្រូវយកចិត្តទុកដាក់ចំពោះផលប៉ះពាល់បន្ថែមលើឥទ្ធិផល នៃការប្រែប្រួលអាកាសធាតុ ដែលកំពុងកើតឡើងស្រាប់។<br>២. សេណារីយ៉ូនៃភាពងាយរងគ្រោះ ផលប៉ះពាល់ និងការបន្សាំ ត្រូវបានរៀបចំឡើង ដោយផ្អែកលើព័ត៌មានវិទ្យាសាស្ត្រដែលអាចប្រើបានយ៉ាងល្អបំផុត និងជាតំរូវការពីមូលដ្ឋាន។<br>៣. កិច្ចអន្តរាគមន៍ត្រូវកែសម្រួលជាព័ត៌មានថ្មីៗដែលអាចប្រើប្រាស់បាន<br>៤. ព័ត៌មានអាកាសធាតុត្រូវផលិតឡើង និងចែកចាយឲ្យបានទូលំទូលាយ ដើម្បីជំនួយដល់ការធ្វើសេចក្តីសម្រេចចិត្តពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ឲ្យបានសុក្រិតល្អ។ |

ដើម្បីស្វែងយល់ អំពីរបៀបថា តើ JPA ត្រូវបានប្រើប្រាស់នៅក្នុងវិធីផ្សេងគ្នា នៅក្នុងបរិបទផ្សេងគ្នាយ៉ាងដូចម្ដេច សូមមើលការបោះពុម្ពរបស់ Southern Voices «ការដាក់គោលការណ៍ទៅក្នុងការអនុវត្ត-បទពិសោធន៍សង្គមស៊ីវិល មកពីជុំវិញពិភពលោកនៃការប្រើប្រាស់ JPA "[2] ដែលត្រូវបានគេយកមកបង្ហាញដូចខាងក្រោម:




ដៃគូភាគច្រើនរបស់គំរោង Southern Voices បានទទួលស្គាល់ថា គោលការណ៍រួមសម្រាប់ការបន្សាំ ជាធនធានមានតម្លៃសម្រាប់ការងាររបស់ពួកគេក្នុងការលើកកម្ពស់ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុដ៏មានប្រសិទ្ធភាព និងមានសមភាព រួមទាំងការដាក់បញ្ចូលគ្នា និងយកចិត្តទុកដាក់ពីតំរូវការសហគមន៍។ នាពេលបច្ចុប្បន្ននេះដៃគូផ្សេងទៀតត្រូវបានលើកទឹកចិត្តអោយសាកល្បង ឧបករណ៍ និងគោលការណ៍ទាំងនេះ ទៅតាមតំរូវការ ប្រសិនបើចាំបាច់សម្រាប់កាលៈទេសៈផ្ទាល់ខ្លួនរបស់ពួកគេ។

**កម្មវិធី** Southern Voices (SV)

ចាប់តាំងពីកិច្ចសន្និសីទបណ្ដាភាគីជាសមាជិកលើកទី១៥ (CoP១៥) នៅទីក្រុង Copenhagen កម្មវិធីរបស់ SV បាន និងកំពុងពង្រឹងបណ្ដាញដែលជាដៃគូក្នុងសកលលោក ដើម្បីធ្វើការតស៊ូមតិ ទាមទារអោយមានគោលនយោបាយ ការប្រែប្រួលអាកាសធាតុដែលផ្ដល់ផលប្រយោជន៍ដល់ប្រជាជនក្រីក្រ និងជនងាយរងគ្រោះ។ តាមរយៈគម្រោងនេះ (Southern

[2] អាចរកបានពីគេហទំព័ររបស់ Southern Voices www.souternvoices.net

Voice on Adaptation) បាននិងកំពុងគាំទ្រសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលចំរុះមួយដែល មានចំនួន ១៤ ស្ថាប័នមកពីតំបន់អាស៊ី អាហ្វ្រិក និង អាមេរិកឡាទីន ដោយផ្តោតលើគោលនយោបាយបន្សាំដែលគាំទ្រប្រជាជនក្រីក្រ។

គម្រោងនេះអាចដំណើរការបាន ដោយមានការសម្របសម្រួលពីអ្នកសម្របសម្រួលចំនួនបីរូប ទៅតាមតំបន់ និងលេខាធិការដ្ឋានមានទីតាំងនៅទីក្រុង Copenhagen ដែលដឹកនាំដោយ អង្គការ CARE ប្រទេសដាណឺម៉ាក។ រាល់ការសម្រេចចិត្តត្រូវបានធ្វើឡើងដោយគណៈកម្មាធិការដឹកនាំមួយដែលមានសមាសភាពពីភាគីពាក់ព័ន្ធគម្រោង និងការផ្តល់អនុសាសន៍បច្ចេកទេសមកពីក្រុមប្រឹក្សាភិបាលបានបង្កើតឡើងដោយក្រុមអ្នកជំនាញការបន្សាំការប្រែប្រួលអាកាសធាតុ។

គម្រោងនេះត្រូវបានឧបត្ថម្ភមូលនិធិដោយ មូលនិធិអាកាសធាតុ និងបរិស្ថាន នៃ CISU /DANIDA តាមរយៈ សមាគមកសាងសមត្ថភាពស្តីពីអាកាសធាតុ រួមមាន CARE Danmark, DanChurchAid (DCA) និង IBIS។

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (The NGO Forum on Cambodia) តាមរយៈគំរោងតាមដានគោលនយោបាយការប្រែប្រួលអាកាសធាតុ/សម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលស្តីពីបរិស្ថាន និងការប្រែប្រួលអាកាសធាតុ (NECA) និង បណ្តាញស្តីពីការប្រែប្រួលអាកាសធាតុកម្ពុជា (CCCN) គឺជាដៃគូមួយរបស់គម្រោងនេះប្រចាំនៅកម្ពុជា ក្នុងគោលបំណងធ្វើឲ្យប្រសើរឡើងនូវសកម្មភាព និងសមត្ថភាពក្នុងចំណោមអង្គការសង្គមស៊ីវិលទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ការអនុវត្ត ការត្រួតពិនិត្យនូវយុទ្ធសាស្ត្រគោលនយោបាយបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ដើម្បីធានាពីផលប្រយោជន៍របស់សហគមន៍ងាយរងគ្រោះ។

អាចរកបានពីគេហទំព័រ www.southernvoices.net

## ទំនាក់ទំនងព័ត៌មាន


| | | | |
|---|---|---|---|
| លោក ភីធើ វីដ (Peter With) អ្នកសម្របសម្រួលកម្មវិធី លេខាធិការដ្ឋាន អង្គការឃែរដាណឺម៉ាក pwith@care.dk | អ្នកស្រី តាន់នៃរ៍ ហ្វូលន័ ពូឡានូស (Tania Guillén Bolaños) អ្នកសម្របសម្រួលថ្នាក់តំបន់នៅអង្គការឃ្លាំមើលឡាទីអាមេរិចដើម្បីការអភិវឌ្ឍន៍ដោយចីរភាព Nicaraguamilenio @humboldt.org.ni | លោក ហរ័បរ វ៉ាឡុកុមូ (Herbert Mwalukomo) អ្នកសម្របសម្រួលថ្នាក់តំបន់សម្រាប់អាហ្វ្រិច CEPA, ប្រទេសម៉ាឡាវី herbert@cepa.org.mw | លោកស្រី វ៉ូស៊ីថា វីហ្សិណាយុគេ (Vositha Wijenayake) អ្នកសម្របសម្រួលថ្នាក់តំបន់សម្រាប់អាស៊ី CANSA, ប្រទេសស្រីលង្កា។ vositha@cansouthasia.net |


## អាស័យដ្ឋាន


**វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា** (The NGO Forum on Cambodia)

ផ្ទះលេខ ៩-១១ ផ្លូវលេខ៤៧៦ សង្កាត់ទួលទំពូង១ រាជធានីភ្នំពេញ

ទូរសព្ទ័ៈ (៨៥៥) ២៣ ២១៤ ៤២៩